# ប្រព័ន្ធ និងរចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន និងជាតិ

## LOCAL, NATIONAL AND GLOBAL SYSTEMS AND STRUCTURES



# តើហេតុអ្វីបានជាពលរដ្ឋសកលត្រូវ យល់ពីប្រព័ន្ធ និងរចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន និងជាតិ?

# ប្រព័ន្ធ និងរចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន និងជាតិ



# រដ្ឋបាលកណ្តាល

| ស្ថាប័ន គ្រប់គ្រង និងសម្រេច | ស្ថាប័នប្រឹក្សានិងពិគ្រោះយោបល់ | ស្ថាប័នត្រួតពិនិត្យ | ស្ថាប័នសម្របសម្រួល |
| --- | --- | --- | --- |
| ព្រះមហាក្សត្រ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អាជ្ញាធរសវនកម្មជាតិ | គណៈរដ្ឋមន្ត្រី |
| នាយករដ្ឋមន្ត្រី | ក្រុមប្រឹក្សាអ្នកច្បាប់ | ស្ថាប័នប្រឆាំងអំពើពុករលួយ | គណៈអន្តរក្រសួង |
| រដ្ឋមន្ត្រី | ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និងវប្បធម៌ | | |

**ស្ថាប័នអនុវត្ត**

- ក្រសួង
- គ្រឹះស្ថានសាធារណៈ
- និយ័តករ

# រដ្ឋបាលកណ្តាល

**ក្រសួង** ៖ ជាស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលបន្ទុកការងារតាមវិស័យ

រូបមន្តគ្រប់គ្រងរដ្ឋបាល

- នយោបាយមជ្ឈការ៖ ក្រសួងគ្រប់គ្រង និងចាត់ចែងសេវាដោយផ្ទាល់
- នយោបាយវិមជ្ឈការបច្ចេកទេស៖ ក្រសួងប្រគល់ភាពជាម្ចាស់លើការគ្រប់គ្រង និងចាត់ចែងសេវាណាមួយទៅឱ្យគ្រឹះស្ថានសាធារណៈ

**គ្រឹះស្ថានសាធារណៈរដ្ឋបាល**

សេវាមានលក្ខណៈរដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ ឬ បច្ចេកទេស

**គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច**

សេវាសាធារណៈមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម

# រដ្ឋបាលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា



# រដ្ឋបាលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា

| នីតិបុគ្គល | | តំណាងរដ្ឋ | | តំណាងប្រជាពលរដ្ឋ |
|---|---|---|---|---|
| រាជធានី ខេត្ត | = | គណៈអភិបាលរាជធានី ខេត្ត | + | ក្រុមប្រឹក្សារាជធានី ខេត្ត |
| ក្រុង ស្រុក ខណ្ឌ | = | គណៈអភិបាលក្រុង ស្រុក ខណ្ឌ | + | ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ |
| ឃុំ សង្កាត់ | = | មេឃុំ ចៅសង្កាត់ | + | ក្រុមប្រឹក្សាឃុំ សង្កាត់ |

# I. ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

កម្ពុជាជាប្រទេសមានអរិយធម៌ និងវប្បធម៌ ចំណាស់មួយ មានប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានជាយូរណាស់មកហើយ និងមានការប្រែប្រួលពីរបបនយោបាយមួយទៅរបបនយោបាយមួយ ដោយផ្អែកទៅតាមស្ថានភាពនយោបាយ ប្រជាសាស្រ្ត ភូមិសាស្រ្ត សេដ្ឋកិច្ច និងសង្គមជាក់ស្តែងក្នុងសម័យកាលនីមួយៗ។

- ព្រះរាជាណាចក្រកម្ពុជាទី២(២០០២-បច្ចុប្បន្ន)
- ព្រះរាជាណាចក្រកម្ពុជាទី២(១៩៩៣-២០០១)
- សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)
- កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)
- សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)
- បន្ទាប់ទទួលបានឯករាជ្យ (១៩៥៤-១៩៧០)
- មុននិងក្នុងសម័យអាណានិគមបារាំង( មុនឆ្នាំ១៩៥៣)

# I. ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា (ត)

## មុននិងក្នុងសម័យអាណានិគមបារាំង( មុនឆ្នាំ១៩៥៣)

- មុនឆ្នាំ១៩០៨ ត្រូវបានបែងចែកជាតំបន់ដែលគ្រប់គ្រងដោយស្ដេចត្រាញ់
- តំបន់នីមួយៗ មានខេត្តចំណុះដែលគ្រប់គ្រងដោយចៅហ្វាយស្រុក
- មានមន្ត្រីក្រោមបង្គាប់ជាអ្នកពាំនាំការបង្គាប់បញ្ជារបស់ចៅហ្វាយស្រុកទៅឱ្យមេស្រុក
- មេស្រុកជាអ្នកគ្រប់គ្រងភូមិដែលត្រូវបានជ្រើសរើសតែងតាំងដោយចៅហ្វាយស្រុកដើម្បីប្រមូលពន្ធ

- ក្រោមអាណានិគមបារាំងបានបង្កើតក្របខណ្ឌច្បាប់ដំបូងសម្រាប់គ្រប់គ្រង**ឃុំ** តាមរយៈក្រឹត្យចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩០៨
- លុបចោលប្រព័ន្ធគ្រប់គ្រងតំបន់ស្ដេចត្រាញ់ ដោយបែងចែកជា**ខេត្ត ស្រុក ឃុំ និងភូមិ**
- ចៅហ្វាយស្រុកក្លាយជាចៅហ្វាយខេត្ត ហើយ មេស្រុកក្លាយជាមេឃុំ
- មេឃុំត្រូវជ្រើសរើសតាមការបោះឆ្នោតដោយប្រជាពលរដ្ឋ
- ឃុំនីមួយៗប្រមូលផ្ដុំដោយភូមិជាច្រើន

- **ក្រឹត្យច្បាប់ឆ្នាំ១៩១៩** ដើម្បីឱ្យបានច្បាស់នូវមុខងារ សមត្ថកិច្ច ចំនួនសមាជិកក្រុមប្រឹក្សាបុគ្គលិក និងថវិការបស់ឃុំ
- ក្រឹត្យច្បាប់ឆ្នាំ១៩១៩ត្រូវបានកែសម្រួលនូវឆ្នាំ១៩២៦ ដោយផ្ដល់ឱ្យឃុំនូវឋានៈជានីតិបុគ្គល និងបានធ្វើឱ្យឃុំក្លាយជារដ្ឋបាលជាក់លាក់មួយក្នុងប្រព័ន្ធរដ្ឋបាលនៅកម្ពុជា
- ពីឆ្នាំ១៩៤៨មកដោយសារសង្គ្រាម ការបោះឆ្នោតនៅឃុំបានផ្អាកទាំងស្រុង ហើយមេឃុំត្រូវតែងតាំងដោយចៅហ្វាយខេត្ត

# II. ទស្សនទាននៃអភិបាលកិច្ចតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ

## អត្ថន័យវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

**វិសហមជ្ឈការ**

ជាការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មអំណាច មុខងារ និងធនធាន ទៅឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ទីរ អង្គភាពក្រោមបង្គាប់របស់ខ្លួន ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន។ក្រុមប្រឹក្សា ឬមន្ទីរ អង្គភាពនោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន

**៣. វិមជ្ឈការ**

ជាការដែលរាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានទៅឲ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនោះ។

## III.ការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា (ថ្នាក់ឃុំ សង្កាត់)

**ឆ្នាំ ២០០១** → **ឆ្នាំ២០០២ ការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សរងាត់


ច្បាប់
ស្តីពី
ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
ច្បាប់
ស្តីពី
ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ (២០០២-២០០៧)



- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់
  - ✓ នីតិវិធីការងារ
  - ✓ ប្រព័ន្ធផែនការ
  - ✓ ការបង្កើតមូលនិធិឃុំ សង្កាត់



**លទ្ធផលវិជ្ជមាន៖**

- លទ្ធផលនយោបាយ
- ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន៖
  - ✓ គម្រោងហេដ្ឋារចនាសម្ព័ន្ធ
  - ✓ គម្រោងផ្តល់សេវាសង្គម
  - ✓ គម្រោងបង្កើនប្រាក់ចំណូល
  - ✓ គម្រោងការពារ និងអភិរក្សធនធានធម្មជាតិ

13

## V. ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

**1. ការបន្តពង្រឹងការគ្រប់គ្រង និងការដឹកនាំការងារកំណែទម្រង់៖**

យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

- ពង្រឹងការចូលរួម និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដឹកនាំ សម្របសម្រួល គ្រប់គ្រង និងអនុវត្តកិច្ចដំណើរការកំណែទម្រង់
- បន្តសម្របសម្រួល និងសហការជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈឱ្យកាន់តែមានភាពស៊ីសង្វាក់គ្នា និងគាំទ្រគ្នាទៅវិញទៅមក
- ពង្រឹងកិច្ចសហការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនដើម្បីធានាដល់ការកៀរគរការចូលរួម និងគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ឱ្យកាន់តែមានភាពសកម្ម និងរស់រវើកបន្ថែមទៀត។

## V. ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

**២. ការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ ការប្រាស្រ័យទាក់ទងសាធារណៈ

- សិក្សាជម្រើសសម្រាប់ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យកាន់តែមានភាពច្បាស់លាស់ ស្របតាមប្រភេទ និងចរិតលក្ខណៈផ្សេងៗគ្នា
- បន្តពិនិត្យ និងកំណត់មុខងារឱ្យបានច្បាស់លាស់រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងចំណោមថ្នាក់ក្រោមជាតិនីមួយៗ
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យ និងអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## V. ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

**៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធនមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន និងមានចំនួនបុគ្គលិកគ្រប់គ្រាន់ ប្រកបដោយឆន្ទៈម្ចាស់ការ មានសមត្ថភាព និងជំនាញវិជ្ជាជីវៈ ស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈជាប្រចាំ។

- ពង្រឹងការអនុវត្តសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិក
- ពង្រឹងការបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំ**អង្គវិជ្ជាជីវៈមន្ត្រីរាជការ ការពិពណ៌នាមុខងារ លក្ខខណ្ឌការងារ ក្រមសីលធម៌ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ**ជាប្រចាំលើលទ្ធផលបំពេញការងារ ព្រមទាំង**ផ្តល់ការលើកទឹកចិត្ត**ដល់បុគ្គលិកដែលបំពេញការងារបានល្អ
- រៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយលើកទឹកចិត្តដល់បុគ្គលិកដែលបំពេញការងារនៅតំបន់ជួបការលំបាក
- អភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ និងជាប្រចាំ(សាលាជាតិរដ្ឋបាលមូលដ្ឋាន សាលាតំបន់

## V. ទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

### ៤. ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជន៍សម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- កំណត់ឲ្យបានច្បាស់លាស់អំពីមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស
- បន្តផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានផ្ទេរនាពេលកន្លងមកឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ និងការបណ្តុះបណ្តាលដល់បុគ្គលិកឱ្យមានជំនាញសមស្របសម្រាប់ការអនុវត្តមុខងារទាំងនោះ
- ពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលកន្លងមក ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តលើការពង្រីក និងការផ្ទេរមុខងារចាំបាច់បន្ថែមទៀតទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ ពង្រឹង និងកែលម្អយន្តការ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈឱ្យមានលក្ខណៈទំនើប សាមញ្ញ ដើម្បីធានាដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋបានឆាប់រហ័ស និងងាយស្រួល